# ព្រះរាជាណាចក្រកម្ពុជា
# ជាតិ សាសនា ព្រះមហាក្សត្រ

២០ កុម្ភៈ ២០១៧

# ផែនការសកម្មភាពជាតិ ២០១៤-២០១៨
# គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស

## របាយការណ៍ពិនិត្យឡើងវិញពាក់កណ្ដាលអាណត្តិ

រ៉ូប៊ី ម៉ូនី ព្រាំ ងា និង ងួន សុផល
អ្នកប្រឹក្សាយោបល់

USAID
ជំនួយពីពលរដ្ឋអាមេរិក

WINROCK INTERNATIONAL

# ការវាយតម្លៃពាក់កណ្ដាលអណត្តិ

## នៃផែនការសកម្មភាពជាតិប្រឆាំងអំពើជួញដូរមនុស្ស

## ២០១៤-២០១៨

របស់គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស

- ការវាយតម្លៃ ធ្វើឡើងដោយ អ្នកជំនាញវាយតម្លៃឯករាជ
- គាំទ្រដោយ ទីភ្នាក់ងារអភិវឌ្ឍន៍អន្តរជាតិ សហរដ្ឋអាមេរិក តាមរយៈអង្គការវិនរ៉ក់អន្តរជាតិ
- យូអិនអាក់ និងកាមបូឌានអាក់

គោលបំណងទី១: វាយតំលៃការប្រព្រឹត្តទៅនៃយន្តការ
ជាតិ គ.ជ.ប.ជ

គោលបំណងទី២: វាយតំលៃសមិទ្ធផលសម្រេចបាន
ក្នុងការអនុវត្តផែនការសកម្មភាពជាតិ

# គុណប្រយោជន៍នៃការវាយតម្លៃ

- រកឲ្យឃើញភាពរីកចម្រើន ចំណុចខ្លាំង និងចំណុចខ្វះខាតក្នុងយន្តការ និងការអនុវត្តផែនការសកម្មភាពជាតិ
- ធ្វើការកែលម្អសកម្មភាព ពាក់កណ្តាលអណត្តទី២ នៃផែនការជាតិ ដើម្បីឆ្លើយតបទៅនឹងបច្ចុប្បន្នភាពនៃអំពើជួញដូរមនុស្ស និងធ្វើឲ្យសម្រេចគោលដៅតាមការគ្រោងទុក

# ដំណើរការនៃការវាយតម្លៃ រយៈពេល បីខែ (តុលា-ធ្នូ ២០១៦)

- ការពិនិត្យឯកសារពាក់ព័ន្ធ
  - ផែនការសកម្មភាពជាតិ ២០១៤-២០១៨
  - ផែនការសកម្មភាពប្រចាំឆ្នាំនៃ គ.ជ.ប.ជ
  - ផែនការសកម្មភាពនៃក្រុមអន្តរក្រសួង
  - ផែនការសកម្មភាពនៃ គ.ខ.ប.ជ
  - របាយការណ៍ គ.ជ.ប.ជ (២០១៤, ២០១៥, ២០១៦)
  - ព្រឹត្តប័ត្រពត៌មាន ទំព័រហ្វេសប៊ុករបស់គ.ជ.ប.ជ
  - របាយការណ៍ផ្សេងទៀតពីអង្គការក្រៅរដ្ឋាភិបាល
- ការសម្ភាសន៍បុគ្គលសំខាន់ៗ
  - ចុះសម្ភាសន៍ប្រមូលទិន្នន័យពីថ្នាក់ដឹកនាំ និង ប្រតិបត្តិករ នៅខេត្តស្វាយរៀង កំពង់ចាម បន្ទាយមានជ័យ និងសៀមរាប
  - ជនគន្លឹះ ក្នុង គ.ជ.ប.ជ គ.ខ.ប.ជ ក្រសួងពាក់ព័ន្ធសំខាន់ៗ

    ដៃគូអភិវឌ្ឍន៍ និងអង្គការក្រៅរដ្ឋាភិបាល

# លទ្ធនៃការស្រាវជ្រាវ ដើម្បីវាយតម្លៃ

# ការប្រព្រឹត្តទៅនៃយន្តការ៖ រចនាសម្ព័ន្ធថ្នាក់ជាតិ

- ភាពខ្លាំង
  - រចនាសម្ព័ន្ធរដ្ឋបាលច្បាស់លាស់នៅ គ ជ ប ជ
  - ថវិកាកើនឡើង
  - ការប្តេជ្ញាចិត្តនិងភាពជាអ្នកដឹកនាំរបស់អគ្គលេខាធិការដ្ឋាន ដឹកនាំដោយអនុប្រធានអចិន្ត្រៃយ៍
  - បានតែងតាំងនៅក្រុមការងារអន្តរក្រសួងនៅថ្នាក់ជាតិ
  - បានតែងតាំងគណៈកម្មាធិការខេត្ត និងក្រុមការងារ
  - មានយន្តការទំនាក់ទំនងងាយស្រួល (ឧ. តេឡេក្រាម)
  - មានការណែនាំ តំរង់ទិស អំពីតួនាទី ភារកិច្ច និងការទទួលខុសត្រូវ របស់បណ្តាថ្នាក់
- បញ្ហាប្រឈម
  - បុគ្គលិកមួយចំនួនសមត្ថភាពមានកម្រិត
  - ឆន្ទៈក្នុងការបំពេញភារកិច្ច និងការទទួលខុសត្រូវ មិនទាន់មានតុល្យភាព (ខ្លះធ្វើច្រើន ខ្លះធ្វើតិច)
  - ថវិកាសម្រាប់ការអនុវត្តសកម្មភាពនៅតាមស្ថាប័ន និងខេត្ត នៅមានកម្រិត

# ការប្រព្រឹត្តទៅនៃយន្តការ ៖ ក្រុមការងារជំនាញអន្តរក្រសួងទាំង៦

(ក្រុមបង្ការ ទប់ស្កាត់ ក្រុមការពារជនរងគ្រោះ ក្រុមអនុវត្តច្បាប់ ក្រុមកិច្ចការយុត្តិធម៌ ក្រុមការងារទេសន្តរប្រវេសន៍ ក្រុមការងារសហប្រតិបត្តិការអន្តរជាតិ)

- ភាពខ្លាំង
  - ក្រុមការងារតាមវិស័យទាំងអស់ មានតួនាទីនិងភារកិច្ចច្បាស់លាស់
  - មានទំនាក់ទំនងល្អជាមួយ អគ្គលេខាធិការដ្ឋានគ.ជ.ប.ជ និងត្រូវបានអញ្ជើញឲ្យចូលរួមកិច្ចប្រជុំ និងការបណ្តុះបណ្តាលផ្សេងៗ
  - ការសហការត្រូវបានពង្រឹង រវាងសមាជិកក្រុមផ្អែកលើតួនាទីនិងការទទួលខុសត្រូវ របស់ក្រសួងស្ថាប័ន
  - ក្រុមការងារអន្តរក្រសួងខ្លះបានជួបប្រជុំ ពិភាក្សាការងារ
- ការប្រឈម
  - ក្រុមការងារ ត្រូវបានមើលឃើញថាមានការងារស្ទួនជាមួយនឹងការងារក្រសួងរឺគណៈកម្មាធិការដទៃ
  - ក្រុមការងារខ្លះមិនបានជួបប្រជុំគ្នា ឬប្រជុំមិនទៀងទាត់តាមការកំណត់
  - សមាជិកក្រុម មិនបានផ្តោតការយកចិត្តទុកដាក់លើភារកិច្ច កំណត់របស់ក្រុមអន្តរវិស័យ ក្នុងការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សឡើយ
  - របាយការណ៍ មិនមានលក្ខណៈប្រមូលផ្តុំ មិនសូវផ្តោតចំបញ្ហា ខ្វះសូចនាករ និងមិនមានទម្រង់ឯកភាព ដើម្បីឲ្យងាយស្រួលក្នុងការបូកសរុបឡើយ

# ការប្រព្រឹត្តទៅនៃយន្តការៈ ថ្នាក់ខេត្ត

- ភាពខ្លាំង
  - ក្របខ័ណ្ឌច្បាប់មានស្រាប់
  - គ.ខ.ប.ជ មានរចនាសម្ព័ន្ធច្បាស់លាស់ជាមួយតួនាទីនិងភារកិច្ចដែលបានកំណត់
  - គ.ខ.ប.ជ អាចចាត់វិធានការលឿននៅពេលដែលករណីការជួញដូរមនុស្សកើតឡើង
  - ទំនាក់ទំនងពីថ្នាក់ជាតិដល់ថ្នាក់ក្រោមជាតិមានភាពរហ័ស
  - សមាជិកគណៈកម្មាធិការអាចធ្វើទំនាក់ទំនងជាមួយគ្នាបានយ៉ាងលឿនផងដែរ
- ការប្រឈម
  - សមាជិកក្រុមការងារកំពុងតែធ្វើការរៀងៗខ្លួនដោយមិនមានទំនាក់ទំនងគ្នាគ្រប់គ្រាន់។
  - ការតាមដានសកម្មភាពមិនគ្រប់គ្រាន់ ករណីខ្លះកើតឡើង តែអាជ្ញាធរមិនបានដឹង
  - មន្ទីរអង្គភាពខ្លះ មានកម្មវិធីការងារច្រើន ខ្វះមន្ត្រី និងមិនមានពេលវេលាចូលរួមកិច្ចប្រជុំឲ្យបានជាប់លាប់ ជាប្រចាំ
  - កង្វះថវិកានិងធនធានមនុស្ស

# អនុសាសន៍

១.រៀបចំកែលម្អផែនការ និងធ្វើឲ្យមុខងាររបស់រួលឲ្យប្រសើរឡើង

- សារៈសំខាន់នៃកិច្ចប្រជុំជាទៀងទាត់
- ធ្វើផែនការរួមគ្នាសម្រាប់សកម្មភាពប្រចាំឆ្នាំ និងកំណត់អាទិភាពឲ្យស្របគ្នារវាងក្រុមការងារ គ.ជ.ប.ជ និង គ.ខ.ប.ជ ដើម្បីធានាក្របខណ្ឌពេលវេលា និងសកម្មភាពឲ្យបានច្បាស់លាស់។
- រៀបចំផែនការប្រចាំឆ្នាំ / ផែនការប្រតិបត្តិសម្រាប់ក្រុមការងារនីមួយៗ ដែលឆ្លើយតបទៅនឹងយុទ្ធសាស្ត្រនៃផែនការសកម្មភាពជាតិ ដែលនឹងជួយសម្រួលដល់ការតាមដាន និងរាយការណ៍។

២.បន្តពង្រឹងសមត្ថភាពរបស់ គ.ជ.ប.ជ និង គ.ខ.ប.ជ

- ប៉ាន់ប្រមាណអំពីតម្រូវការសមត្ថភាព របស់ គ.ជ.ប.ជ និង គ.រ/ខ.ប.ជ និងត្រូវមានផែនការអភិវឌ្ឍសមត្ថភាពមន្ត្រីអនុវត្តការងារគ្រប់ថ្នាក់ ។

## អនុសាសន៍ (ត)

៣.អភិវឌ្ឍន៍ឧបករណ៍ត្រួតពិនិត្យនិងវាយតម្លៃ ដោយផ្អែកលើសូចនាករដើម្បីអាចចងក្រងនូវការរីកចំរើន ជោគជ័យនិងបញ្ហាប្រឈមតមនឹងសូចនាករ

- ទិន្នន័យដែលបានមកពីប្រភពផ្សេងៗគួរត្រូវផ្ទៀងផ្ទាត់ជាមួយសូចនាករ នៃផែនការសកម្មជាតិ
- ប្រព័ន្ធរាយការណ៍មួយដែលត្រូវបានបង្កើតឡើង និងដឹកនាំដោយ គ.ជ.ប.ជ ត្រូវរៀបចំជាទម្រង់របាយការណ៍ ខែ ត្រីមាស ដែលឆ្លើយតបទៅនឹងសូចនាករដែលបានកំណត់ សម្រាប់ឲ្យក្រុមការងារអន្តរក្រសួង និង គ.ខ.ប.ជ ធ្វើរបាយការណ៍ដែលសាមញ្ញ ច្បាស់លាស់ និងងាយស្រួលបូកសរុប ។
- ប្រព័ន្ធសំរបសំរួលមួយ (មូលដ្ឋានទិន្នន័យ) គួរតែត្រូវបានរៀបចំរួចជាស្រេច ដើម្បីធានាថា ទិន្នន័យសំខាន់ៗ

  ត្រូវបានប្រមូលផ្តុំ បូកសរុប សំរាប់ការវាយតំលៃនៅចុងបញ្ចប់អណត្តិនៃផែនការសកម្មភាពជាតិ។

## អនុសាសន៍ (ត)

- បង្កើនថវិកាសម្រាប់សកម្មភាពប្រឆាំងការជួញដូរមនុស្ស
  - ថវិកាសម្រាប់ការអនុវត្តផែនការ ត្រូវបានគ្រោងទុក និងគួរត្រូវទទួលបានគ្រប់គ្រាន់ តាមការគ្រោងទុក ។
  - ខ្ទង់ថវិកានៅថ្នាក់ក្រោមជាតិ គួរត្រូវបានបង្កើតដោយឡែក សម្រាប់សកម្មភាពប្រឆាំងការជួញដូរមនុស្ស ដើម្បីប្រសិទ្ធិភាពនិងលទ្ធផលការងារល្អ។

# សមិទ្ធិផលនានានៃការអនុវត្តន៍នៃផែនការសកម្មភាពជាតិ

- យុទ្ធសាស្រ្តទី ១: ការពង្រឹងច្បាប់និងគោលនយោបាយនិងលើកកំពស់កិច្ចសហប្រតិបត្តិការ
- យុទ្ធសាស្រ្តទី ២ : លើកកម្ពស់ការបង្ការទប់ស្កាត់
- យុទ្ធសាស្រ្តទី៣ : ពង្រឹងប្រព័ន្ធយុត្តធម៌ព្រហ្មទណ្ឌឆ្លើយតបនឹងការជួញដូរមនុស្ស
- យុទ្ធសាស្រ្តទី ៤ : ការការពារជនរងគ្រោះជាមួយនឹងយេនឌ័រនិងអាយុសមស្របប្រកបដោយការគាំទ្រគុណភាព

## អនុសាសន៍បន្ថែមះ

បន្តការអភិវឌ្ឍនិងកែលម្អការអនុវត្តច្បាប់ជាតិ គោលនយោបាយសេចក្តីណែនាំនិងផែនការ

- *ផ្តល់អាទិភាពដល់ការរៀបចំបញ្ចប់កិច្ចព្រមព្រៀងជាមួយនឹងប្រទេស/ តំបន់ដែលមានការធ្វើចំណាកស្រុកខ្ពស់ ប្រឋុយប្រថាននឹងអំពើជួញដូរមនុស្ស ។*
- *បន្តធ្វើឱ្យប្រសើរឡើងនូវយន្តការកិច្ចសហប្រតិបត្តិការអន្តរជាតិដើម្បីលើកកម្ពស់ទំនាក់ទំនងនិងធ្វើសកម្មភាពរួមគ្នារវាងប្រទេសនិងប្រទេស ។*

# សេចក្តីសន្និដ្ឋាន(ត)

- ការរីកចម្រើនគួរឱ្យកត់សម្គាល់ត្រូវបានធ្វើឡើងឆ្ពោះទៅរកការបញ្ចប់នៃការអាទិភាព ផែនការសកម្មជាតិ។ ការរៀបរាប់លម្អិតដូចបានបរិយាយខាងលើនៅក្នុងផ្នែកនានាដែលទាក់ទងនឹងយុទ្ធសាស្ត្រនីមួយៗ ។ វាជាការលំបាកក្នុងការប៉ាន់ប្រមាណកម្រិតនៃការរីកចម្រើនឆ្ពោះទៅរកសូចនាករនីមួយៗដោយសារតែខ្វះទិន្នន័យគ្រប់គ្រាន់សម្រាប់សូចនករខ្លះ។
- ប៉ុន្តែ នៅពេលពិនិត្យមើលទិន្នផលទាំងនេះ វាច្បាស់ណាស់ថាយុទ្ធសាស្ត្រទាំងអស់មានការរីកចម្រើនគួរឲ្យកត់សម្គាល់នៅក្នុងលទ្ធផលភាគច្រើន។ លទ្ធផលដែលគំរូវយកចិត្តទុកដាក់បំផុតគឺបង្កើតប្រព័ន្ធត្រួតពិនិត្យថែមទៀត។